Disability Rights California
*ប្រព័ន្ធការការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*ទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# វិធីធ្វើឲ្យក្រុមហ៊ុនឯកជនផ្តល់ជូនឧបករណ៍បច្ចេកវិជ្ជាជំនួយ

***ខែសីហា ឆ្នាំ 2015 ឯកសារបោះពុម្ពផ្សាយលេខ 5576.06 - Cambodian***

## 1. តើមានច្បាប់អ្វីសម្រាប់ប្រើជាមួយក្រុមហ៊ុនឯកជន?

ជាទូទៅ យើងមានច្បាប់រដ្ឋាភិបាលសហព័ន្ធពីរ និងច្បាប់រដ្ឋាភិបាលរដ្ឋពីរ ដែលអាចតម្រូវឲ្យក្រុមហ៊ុនឯកជនផ្តល់ឧបករណ៍បច្ចេកវិជ្ជាជំនួយ (assistive technology) ជូនអ្នក ។ ច្បាប់ទាំងពីររបស់រដ្ឋាភិបាលសហព័ន្ធគឺ ៖

- ក្រមជនពិការសហរដ្ឋអាមេរិក (ADA, Americans with Disabilities Act)
- វគ្គទី 504 នៃក្រមស្តានីតិសម្បទា (Rehabilitation Act) (Section 504)

ច្បាប់ទាំងពីររបស់រដ្ឋាភិបាលរដ្ឋគឺ ៖

- ក្រមស្តីអំពីសិទ្ធិពលរដ្ឋអ៊ុនរូ (Unruh Civil Rights Act); និង
- ក្រមរដ្ឋប្បវេណីកាលីហ្វ័រនីញ៉ា (California Civil Code) វគ្គទី 54

**<u>ច្បាប់រដ្ឋាភិបាលសហព័ន្ធ</u>**

1. វគ្គទី 504 នៃក្រមស្តានីតិសម្បទា

   Section 504 ហាមឃាត់មិនឲ្យមានការរើសអើងដោយសារពិការភាព នៅក្នុងកម្មវិធី និងសកម្មភាពដែលផ្តល់ដោយភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធ និងភ្នាក់ងារដទៃទៀតដែលបានទទួលមូលនិធិឧបត្ថម្ភពីរដ្ឋាភិបាលសហព័ន្ធ ។ ត្រង់នេះ គឺមានរួមបញ្ចូលនូវការផ្តល់ជូនសិទ្ធិចូលរួមកម្មវិធីសាធារណៈប្រកបដោយប្រសិទ្ធិភាព និងការផ្តល់ជូនជនពិការនូវ

គោលនយោបាយ ការអនុវត្ត និងទម្រង់ការប្រកបដោយការកែសម្រួលសមរម្យ តាមភាពចាំបាច់ ដើម្បីឲ្យពួកគេអាចប្រើប្រាស់សេវាសាធារណៈបាន ។

2. *ក្រមជនពិការសហរដ្ឋអាមេរិក (ADA, Americans with Disabilities Act)*

   Title III នៃ ADA ហាមឃាត់មិនឲ្យរើសអើងចំពោះមនុស្សដោយសារពិការភាព ពីសំណាក់កន្លែងសម្រាប់សាធារណៈជនដែលជាក្រុមហ៊ុនឯកជនដែលបើកបម្រើជាសាធារណៈ ។ ឧបញ្ញត្តិនេះត្រូវបានបកប្រែឲ្យផ្តល់ការការពារដូចគ្នាដល់ជនពិការ ដូចមានចែងក្នុង Section 504 ។  ទីកន្លែងសម្រាប់សាធារណៈជនគឺជាក្រុមហ៊ុនឯកជនដែលបើកបម្រើជាសាធារណៈ ហើយរួមបញ្ចូលកន្លែងនានា ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន រោងមហោស្រព សាលប្រជុំ ហាងទំនិញ ធនាគារ ជំនួញផ្នែកសេវាកម្ម មន្ទីរពេទ្យ ការិយាល័យគ្រូពេទ្យ ស្ថានីយគមនាគមន៍ សារមន្ទីរ សួនសត្វ សាលារៀនឯកជន មណ្ឌលថែទាំកុមារពេលថ្ងៃ និងក្លិបហាត់ប្រាណ ។

**<u>ច្បាប់រដ្ឋាភិបាលរដ្ឋ</u>**

ក្រម Unruh និងក្រមរដ្ឋប្បវេណី Section 54 គឺជាច្បាប់របស់រដ្ឋកាលីហ្វ័រនីញ៉ាដែលហាមឃាត់ក្រុមហ៊ុនឯកជនមិនឲ្យមានការរើសអើងចំពោះជនពិការ ហើយមានផ្តល់ជូនដំណោះស្រាយពីអ្វីដែលមានចែងក្នុង ADA និង Section 504 ។

1. *ក្រមស៊ីអំពីសិទ្ធិពលរដ្ឋអ៊ុនរូ*

   ក្រមអ៊ុនរុហាមឃាត់មិនឲ្យមានការរើសអើងចំពោះមនុស្សដោយសារពិការភាព ពីសំណាក់អង្គភាពជំនួញ ។ ការប្រព្រឹត្តិល្មើសចំពោះ Section 504 និង ADA ក៏ជាការប្រព្រឹត្តិល្មើសចំពោះក្រម Unruh  ដែរ ។ ក្រម Unruh ក្រម រដ្ឋប្បវេណីរដ្ឋកាលីហ្វ័រនីញ៉ា វគ្គទី 51, *et seq.*

2. *ក្រមជនពិការ (Disabled Persons Act) ក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រនីញ៉ា វគ្គទី 54*

   ក្រមរដ្ឋប្បវេណី វគ្គទី 54 ផ្តល់ជូនដល់អ្នកដែលមានបញ្ហាសុខភាព និងជនពិការ នូវសិទ្ធិដូចគ្នានឹងសាធារណៈជនទូទៅ ដើម្បីទទួលបានផលប្រយោជន៍ពីសេវាកម្ម ឬផលិតផលរបស់ក្រុមហ៊ុន ។ ការប្រព្រឹត្តល្មើសចំពោះ Section 504 និង ADA ក៏ជាការប្រព្រឹត្តល្មើសចំពោះក្រម

រដ្ឋប្បវេណីរដ្ឋកាលីហ្វ័រនីញ៉ា វគ្គទី 54 ផងដែរ ។ ក្រមរដ្ឋប្បវេណី វគ្គទី 54 និងវគ្គដែលពាក់ព័ន្ធគ្នា គឺនិយាយអំពីអង្គភាពវេជ្ជសាស្ត្រ មធ្យោបាយដឹកជញ្ជូនទូទៅទាំងអស់ (យន្តហោះ រថភ្លើង រថយន្តក្រុង ។ល។) អង្គភាពទូរស័ព្ទ ភ្នាក់ងារចិញ្ចឹមបីបាច់ សាលារៀនឯកជន កន្លែងស្នាក់នៅ កន្លែងសម្រាប់សាធារណៈជន និងទីកន្លែងផ្សេងទៀតសម្រាប់សាធារណៈជនប្រើប្រាស់ ។ ក្រមជនពិការ ក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រនីញ៉ា វគ្គទី 54, *et seq.*

## 2. នរណាដែលទទួលបានការការពារពីការរើសអើងដោយក្រុមហ៊ុនឯកជន?

ស្ថិតក្រោមនិយមន័យទាំងរបស់រដ្ឋាភិបាលសហព័ន្ធ និង របស់រដ្ឋាភិបាលរដ្ឋស្តីអំពីពិការភាព មនុស្សភាគច្រើនដែលមានពិការភាពរាងកាយ និងខួរក្បាល ដែលបង្កឲ្យមានដែនកំណត់រាងកាយ និងខួរក្បាល ត្រូវបានទទួលការការពារទាំងអស់ ។ និយមន័យរបស់ច្បាប់រដ្ឋាភិបាលសហព័ន្ធ និងច្បាប់រដ្ឋាភិបាលរដ្ឋ ស្តីអំពីពិការភាព មានបង្ហាញជូនខាងក្រោម ។

<u>**ច្បាប់រដ្ឋាភិបាលសហព័ន្ធ**</u>

Title III នៃ ADA ការពារជនពិការ មិនឲ្យមានការរើសអើងពីក្រុមហ៊ុនឯកជន ។ ក្រោម ADA ពាក្យថាពិការភាព មានន័យថា ៖

1. ការមានពិការភាពរាងកាយ ឬខួរក្បាល ដែលរំខានខ្លាំងក្លាចំពោះសកម្មភាព សំខាន់ៗមួយ ឬច្រើនក្នុងជីវិតរបស់អ្នក (ដូចជាសកម្មភាពអនាម័យរាងកាយ ការធ្វើសកម្មភាពហត្ថកម្ម ការដើរ ការមើល ការស្តាប់ ការនិយាយ ការដកដង្ហើម ការរៀនសូត្រ ឬការធ្វើការ) ។

    ក. ត្រង់នេះ គឺរួមបញ្ចូលនូវ ដែនកំណត់ចំពោះមុខងារសំខាន់ៗរបស់រាងកាយ (ដូចជាប្រព័ន្ធភាពស៊ាំនឹងមេរោគ ការលូតលាស់តាមប្រក្រតីរបស់កោសិកា ការរំលាយអាហារ ការបត់ជើងធំ លំពែង ខួរក្បាល ប្រព័ន្ធដកដង្ហើម ចរាចរណ៍ឈាម ក្រពេញបញ្ចេញអ័រម៉ូន និងមុខងារបន្តពូជ) ឬ

2. មានកំណត់ត្រាពិការភាពបែបនេះ (ដូចជាស្ថានភាពចុះខ្សោយមុខងាររាងកាយ) ឬ

3. ត្រូវបានចាត់ទុកថាមានពិការភាពបែបនេះ (ដូចជាមនុស្សដែលរលាកភ្លើងក្នុងកម្រិតធ្ងន់ តែមិនមានពិការភាព) ។

42 ក្រមសហរដ្ឋអាមេរិក (U.S.C., United States Code) វគ្គទី 12102(2); 28 ក្រមនិយត្តកម្មសហព័ន្ធ (C.F.R., Code of Federal Regulations) វគ្គទី 36.104 ។

**<u>ច្បាប់រដ្ឋាភិបាលរដ្ឋ</u>**

ផ្ទុយពីច្បាប់រដ្ឋាភិបាលសហព័ន្ធ ច្បាប់រដ្ឋាភិបាលរដ្ឋ គឺគ្រាន់តែនិយាយចំពោះ "ដែនកំណត់" នៃសកម្មភាពជីវិតសំខាន់ៗ ជាជាង "ដែនកំណត់ធ្ងន់ធ្ងរ" នៃសកម្មភាពជីវិតសំខាន់ៗ ។ ក្រមរដ្ឋាភិបាលរដ្ឋកាលីហ្វ័រនីញ៉ា (California Government Code) វគ្គទី 12926.1(d) ក្រមរដ្ឋាភិបាលរដ្ឋកាលីហ្វ័រនីញ៉ា វគ្គទី 12926(j)(1)(A), (m)(1)(B)(i) ។

## 3. តើច្បាប់ទាំងអស់នេះ ហាមឃាត់ចំពោះការរើសអើងប្រភេទណាខ្លះ?

ច្បាប់ទាំងអស់នេះ ហាមឃាត់ក្រុមហ៊ុនឯកជនមិនឲ្យមានការរើសអើងចំពោះជនពិការ ។ ត្រង់នេះ មានរួមបញ្ចូលនូវ ការចាត់សកម្មភាព ឬការបដិសេធមិនព្រមចាត់សកម្មភាពដែលសមរម្យ ដែលមានបំណង ឬទំនងជាមានការបដិសេធចំពោះជនពិការពីការប្រើប្រាស់សិទ្ធិ ឯកសិទ្ធិ អត្ថប្រយោជន៍ ឬឱកាសណាមួយ ដែលមនុស្សទូទៅអាចប្រើប្រាស់បាន ។ ឧបញ្ញត្តិមួយចំនួននៃច្បាប់នេះ មានរួមបញ្ចូលនូវ ៖

1. ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដែលអាចជាការជម្រុះចេញនូវបុគ្គលជាជនពិការដែលមានគុណវឌ្ឍិគ្រប់គ្រាន់ ។ 28 C.F.R. វគ្គទី 36.301

2. ការបដិសេធមិនផ្តល់ឲ្យអ្នកនូវសិទ្ធិប្រើប្រាស់ពេញលេញ និងស្មើគ្នាចំពោះទំនិញ ឬសេវាកម្មរបស់អង្គភាពឯកជន ។ ត្រង់នេះ គឺរួមបញ្ចូលនូវការខកខានមិនបានផ្តល់ការជួយ អត្ថប្រយោជន៍ និងសេវាកម្ម ដែលធ្វើឲ្យអ្នកមានឱកាសស្មើគ្នានឹងអ្នកដទៃ ក្នុងការទទួលបានលទ្ធផលដូចគ្នា ទទួលបានផលប្រយោជន៍ដូចគ្នា ឬឈានដល់កម្រិតជោគជ័យដូចគ្នាទៅនឹងសិស្សដែលមិនមានពិការភាព ។ 28 C.F.R. វគ្គទី 36.201(a)

3. ការផ្តល់ឲ្យអ្នកនូវអត្ថប្រយោជន៍ ឬសេវាកម្មដោយឡែក ឬខុសពីអ្វីដែលផ្តល់ឲ្យអ្នកដទៃ លុះត្រាតែការធ្វើបែបនោះមានភាពចាំបាច់ក្នុងការផ្តល់ឲ្យអ្នកនូវអត្ថប្រយោជន៍ ឬសេវាកម្មប្រកបដោយប្រសិទ្ធភាព ។ 28 C.F.R. វគ្គទី 36.202(b)

4. ការខកខានរៀបចំផ្តល់ជូនសេវាកម្ម កម្មវិធី និងសកម្មភាព នៅក្នុងបរិស្ថានដែលមានភាពសមាហរណកម្មច្រើនបំផុត ដែលសមរម្យចំពោះតម្រូវការរបស់អ្នក ។ 28 C.F.R. វគ្គទី 36.203

5. ការប្រើលក្ខណៈវិនិច្ឆ័យ និងវិធីសាស្រ្ត ចំពោះការរៀបចំដែលបដិសេធមិនឲ្យអ្នកអាចចូលរួមក្នុងកម្មវិធី និងសកម្មភាពសាធារណៈ ។ 28 C.F.R. វគ្គទី 36.204

6. ការធ្វើឲ្យបន្តមានការរើសអើង ដោយការផ្តល់ជំនួយដែលចំបាច់ដល់ភ្នាក់ងារណាមួយ ដែលរើសអើងចំពោះពិការភាព ។ 28 C.F.R. វគ្គទី 36.204 និង

7. ការសងសឹកចំពោះអ្នក ដោយសារអ្នកអនុវត្តន៍សិទ្ធិរបស់ខ្លួន ។ 28 C.F.R. វគ្គទី 36.206 ។

## 4. តើនៅពេលណាដែលក្រុមហ៊ុនឯកជនត្រូវផ្តល់ឧបករណ៍បច្ចេកវិជ្ជាជំនួយដល់ខ្ញុំ?

ក្រុមហ៊ុនឯកជន ត្រូវផ្តល់ឲ្យអ្នកនូវឧបករណ៍បច្ចេកវិជ្ជាជំនួយ ដែលអាចជួយអ្នកក្នុងការចូលរួមក្នុងសេវាកម្ម ឬកម្មវិធីរបស់ពួកគេ ប្រសិនបើបច្ចេកវិជ្ជានោះ ៖ 1) គឺជា “ឧបករណ៍ ឬសេវាកម្មជំនួយ” ដែលអនុញ្ញាតឲ្យអ្នកអាចទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាព ឬ 2) គឺជាការកែសម្រួលប្រកបដោយភាពសមរម្យ ចំពោះគោលនយោបាយ ទម្រង់ការ ឬការអនុវត្តរបស់អាជីវកម្ម ប្រសិនបើការកែសម្រួលនោះវាមិនបង្កឲ្យមានបន្ទុកហិរញ្ញវត្ថុ ឬការកែប្រែនូវគោលការណ៍គ្រឹះនៃកម្មវិធីសាធារណៈទេនោះ ។ 28 ក្រមនិយត្តកម្មសហព័ន្ធ (C.F.R.) វគ្គទី 36.303 ។ ក្រុមហ៊ុនឯកជន ក៏ត្រូវផ្តល់ជូននូវឧបករណ៍ ឬសេវាកម្មជំនួយ នៅពេលដែលចាំបាច់ផងដែរ ដើម្បីធានាបានថា ជនពិការមានឱកាសស្មើភាពគ្នា ដើម្បីទទួលប្រយោជន៍ពីផលិតផល ឬសេវាកម្មរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនឯកជនមិនត្រូវផ្តល់ឧបករណ៍បច្ចេកវិជ្ជាជំនួយទេ ប្រសិនបើវាគឺជា “ឧបករណ៍ផ្ទាល់ខ្លួន” ដែលអ្នកត្រូវប្រើវា

នៅក្រៅកិច្ចការស្នូល ។[1]

**<u>ឧបករណ៍ និងសេវាកម្មជំនួយ</u>**

ក្រុមហ៊ុនឯកជន ត្រូវផ្តល់ឲ្យបុគ្គលដែលស្ថិតក្នុងភាពពិការដែលមានគុណវឌ្ឍិគ្រប់គ្រាន់ នូវ "ឧបករណ៍ និងសេវាកម្មជំនួយ" សមរម្យ ដើម្បីជួយឲ្យពួកគេអាចទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាព ក្នុងការដាក់ពាក្យសុំ ឬចូលរួមក្នុងកម្មវិធីសាធារណៈ ។ 42 U.S.C. វគ្គទី 12182(b)(2)(iii), 28 C.F.R. វគ្គទី 36.303 ។

ឧទាហរណ៍នៃឧបករណ៍ និងសេវាកម្មជំនួយ មានជាអាទិ៍ ៖

1. អ្នកបកប្រែភាសាដែលមានសមត្ថភាព អ្នកកត់ត្រា សេវាកម្មវាយបញ្ចូលភាសានិយាយ សម្ភារៈជាលាយល័ក្ខណ៍អក្សរ ការប្តូរគ្នានូវកំណត់ត្រាជាលាយល័ក្ខណ៍អក្សរ ឧបល័របំពងសម្លេងទូរស័ព្ទដៃ ឧបករណ៍ជំនួយក្នុងការស្តាប់ ។ ទូរស័ព្ទដែលអាចប្រើបានជាមួយនឹងឧបករណ៍ជំនួយការស្តាប់ ការដាក់ចំណងជើងបើក និងបិទ ឧបករណ៍ទូរគមនាគមន៍ ការបង្ហាញអក្សរក្នុងវីដេអូ ។ល។

2. អ្នកអានដែលមានសមត្ថភាព កាសែតអក្សរ ការថតសម្លេង ឧបករណ៍ពុម្ពអក្សរសម្រាប់មនុស្សពិការភ្នែក ឧបករណ៍សម្រាប់បោះពុម្ពអក្សរធំៗ ។ល។

3. ការទទួលបាន ឬការកែប្រែសម្ភារៈ ឬឧបករណ៍ និង

4. សេវាកម្ម និងសកម្មភាពផ្សេងទៀតដែលស្រដៀងគ្នា ។

បច្ចេកវិជ្ជាខ្លះ ដែលអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រោមផ្នែកនេះ មានដូចជា កម្មវិធីអានអក្សរលើអេក្រង់ ការពង្រីកអក្សរ កម្មវិធីចេះស្គាល់ម្ចាស់សម្លេង និងការវាយពាក្យដែលនិយាយក្នុងកាសែតក្នុងពេលតែមួយ (CART, Captioned Audio Realtime Transcription) ។ ត្រង់នេះ អាច

---

[1] សម្រាប់ព័ត៌មានបន្ថែម សូមអាន ប្រសិទ្ធិភាពនៃការទំនាក់ទំនង *Effective Communication* របស់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក, (U.S. Department of Justice) តាមអាសយដ្ឋាន http://www.ada.gov/effective-comm.htm

រួមបញ្ចូលនូវបច្ចេកវិជ្ជាមួយចំនួន សម្រាប់ជាជំនួយក្នុងការទំនាក់ទំនង ។

ក្នុងការកំណត់ថាតើឧបករណ៍ និងសេវាកម្មជំនួយបែបណា ដែលមានភាពចាំបាច់ ក្រុមហ៊ុនឯកជន ត្រូវធ្វើការពិចារណាចម្បងចំពោះការស្នើសុំរបស់បុគ្គលម្នាក់ៗ ។ ក្រុមហ៊ុនឯកជន ត្រូវផ្តល់ឲ្យនូវឧបករណ៍ និងសេវាកម្មជំនួយ ក្នុងទ្រង់ទ្រាយមួយដែលអាចប្រើបាន ឲ្យបានទាន់ពេល  និងទៅតាមស្ថានភាពដែលអាចការពារឯកជនភាព និងឯករាជ្យភាពរបស់បុគ្គលជាជនពិការ ។

ក្រុមហ៊ុនឯកជន ដែលទំនាក់ទំនងជាមួយនឹងសាធារណៈជន តាមទូរស័ព្ទ ត្រូវប្រគល់ជូននូវប្រព័ន្ធទូរគមនាគមន៍ សម្រាប់ទំនាក់ទំនងជាមួយនឹងមនុស្សដែលមានពិការភាពចំពោះការស្តាប់ និងការនិយាយ ។  28 C.F.R. វគ្គទី 36.303 ។ អ្វីៗទាំងអស់នេះ អាចរួមបញ្ចូលនូវ TTY (ទូរស័ព្ទអក្សរ) វីដេអូបញ្ជូនពីចម្ងាយ  VRI (វីដេអូបកប្រែពីចម្ងាយ) ទូរស័ព្ទជាវីដេអូ និងឧបករណ៍ស្រដៀងគ្នានេះ ។

ក្រុមហ៊ុនឯកជន ក៏ត្រូវផ្តល់ជូននូវឧបករណ៍ ឬសេវាកម្មជំនួយ នៅពេលដែលចាំបាច់ផងដែរ ដើម្បីធានាបានថា ជនពិការ មានឱកាសស្មើភាពគ្នា ដើម្បីទទួលប្រយោជន៍ពីផលិតផល ឬសេវាកម្មរបស់ខ្លួន ។ 42 U.S.C. វគ្គទី 12182(b)(2)(iii) ។ ត្រង់នេះ អាចរួមបញ្ចូលនូវ ការផ្តល់ជូនសម្ភារៈក្នុងទ្រង់ទ្រាយផ្សេងទៀត ដូចជាទ្រង់ទ្រាយអេឡិចត្រូនិក ឬជាអក្សរសម្រាប់មនុស្សពិការភ្នែក ការផ្តល់ជូនកម្មវិធីដូចជាកម្មវិធីពង្រីកអក្សរ ឬកម្មវិធីអានពាក្យក្នុងអេក្រង់ ឬកុំព្យូទ័រសាធារណៈ ឬដោយការផ្តល់ជូននូវបច្ចេកវិជ្ជាមួយចំនួនផ្សេងទៀត ដើម្បីជាជំនួយក្នុងការទំនាក់ទំនង ។  ការផ្តល់ជូននូវឧបករណ៍បច្ចេកវិជ្ជាជំនួយ គឺជាវិធីមួយក្នុងចំណោមវិធីទាំងឡាយ ដែលក្រុមហ៊ុនឯកជន អាចជួយអ្នកបាន ។

## <u>**ការកែសម្រួលប្រកបដោយភាពសមរម្យ**</u>

ក្រុមហ៊ុនឯកជនត្រូវធ្វើការកែសម្រួលឲ្យបានសមរម្យ ចំពោះគោលនយោបាយការអនុវត្ត និងទម្រង់ការរបស់ខ្លួន ទៅតាមពេលដែលចាំបាច់ ដើម្បីផ្តល់ជូននូវការយកចិត្តទុកដាក់ដូចគ្នាដល់ជនពិការ ។ 28 C.F.R. វគ្គទី 36.302 ។

ជនពិការ ត្រូវទទួលខុសត្រូវចំពោះការស្នើសុំការសម្រួលប្រកបដោយភាពសមរម្យ ហើយអាចត្រូវផ្តល់ជូនការគាំទ្រពីផ្នែកវេជ្ជសាស្ត្រ ដើម្បីបញ្ជាក់ថាបុគ្គលរូបនេះមានសេចក្តីត្រូវការ ចំពោះការកែសម្រួលនានាពាក់ព័ន្ធនឹងពិការភាពរបស់ខ្លួន ។ ការគាំទ្រវេជ្ជសាស្ត្រ មិនចាំបាច់ត្រូវបង្ហាញពីលក្ខណៈនៃពិការភាពឡើយ ។ ខ្ញុំគ្រាន់តែបង្ហាញពីដែនកំណត់ដែលបណ្តាលពីពិការភាព ហើយបើអាចទៅរួច

ត្រូវណែនាំចំពោះការកែសម្រួលដែលសមរម្យ ឬណែនាំចំពោះឧបករណ៍បច្ចេកវិជ្ជាជំនួយ ដែលអាចជួយអ្នកឲ្យប្រើឧបករណ៍ ឬសេវាកម្មទាំងអស់នោះបាន ។ ប្រសិនបើបានការអនុញ្ញាតឲ្យធ្វើការកែសម្រួល ក្រុមហ៊ុនឯកជនត្រូវជាអ្នកចេញថ្លៃការចំណាយនេះ ។

## 5. តើខ្ញុំអាចស្នើសុំឧបករណ៍បច្ចេកវិជ្ជាជំនួយពីក្រុមហ៊ុនឯកជនបានដោយរបៀបណា?

យើងខ្ញុំសូមណែនាំឲ្យអ្នកលើកជាសំណើដើម្បីស្នើសុំឧបករណ៍បច្ចេកវិជ្ជាជំនួយជាលាយល័ក្ខណ៍អក្សរ ដោយពន្យល់ ៖ 1) ថាអ្នកជាមនុស្សពិការ (បើទោះបីជាអ្នកមិនចាំបាច់ប្រាប់គេថាអ្នកពិការអ្វីក៏ដោយ) 2) អ្វីដែលពិការភាពរបស់អ្នកមានការប៉ះពាល់ចំពោះលទ្ធភាពរបស់អ្នកក្នុងការទទួលបានផលប្រយោជន៍ពីសេវាកម្ម ឬផលិតផលរបស់ក្រុមហ៊ុននោះ 3) ការកែសម្រួលជាក់លាក់ដែលអ្នកត្រូវការ បូករួមទាំងឧបករណ៍បច្ចេកវិជ្ជាជំនួយ និង 4) កាលបរិច្ឆេទដែលអ្នកចង់បានចម្លើយចំពោះការស្នើសុំរបស់អ្នក ។

## 6. តើខ្ញុំត្រូវតែផ្តល់ភស្តុតាងអំពីពិការភាពរបស់ខ្ញុំ ដើម្បីអាចទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយពីក្រុមហ៊ុនឯកជនដែរឬទេ?

អ្នកអាចត្រូវផ្តល់ភស្តុតាងបញ្ជាក់ថាអ្នកជាមនុស្សពិការ តែអ្នកមិនចាំបាច់ប្រាប់គេថាអ្នកពិការអ្វីឡើយ គឺគ្រាន់តែប្រាប់គេថាវាធ្វើឲ្យមានដែនកំណត់ចំពោះរាងកាយអ្នកយ៉ាងដូចម្តេចប៉ុណ្ណោះ ។ ព័ត៌មាននេះអាចមានសារៈសំខាន់ ប្រសិនបើតម្រូវការចំពោះឧបករណ៍បច្ចេកវិជ្ជាជំនួយមិនបង្ហាញឲ្យឃើញច្បាស់ ដោយសារក្រុមហ៊ុនឯកជនអាចផ្តល់ឲ្យបានតែការកែសម្រួលដែលសមរម្យ បូករួមទាំងឧបករណ៍ និងសេវាកម្មជំនួយចំពោះពិការភាពដែលគេបានដឹង ។ បើពិការភាពរបស់អ្នកវាមិនបានបង្ហាញឲ្យឃើញជាក់លាក់ទេនោះ ឬមួយប្រសិនបើក្រុមហ៊ុនឯកជនមិនអាចផ្ទៀងផ្ទាត់បានអំពីពិការភាពរបស់អ្នក ដោយសារតែគេទាក់ទងជាមួយអ្នកតែតាមទូរស័ព្ទ ពួកគេអាចស្នើសុំភស្តុតាងបញ្ជាក់ពិការភាព និងតម្រូវការរបស់អ្នកសម្រាប់ការកែសម្រួលដែលសមហេតុផល ។ ដើម្បីបង្ហាញថា អ្នកមានសិទ្ធិទទួលបានការកែសម្រួលសមហេតុផល អ្នកអាចត្រូវស្នើសុំលិខិតពីគ្រូពេទ្យ ឬអ្នកឯកទេសផ្សេងទៀត ដែលជាមនុស្សស្គាល់អ្នក និងដឹងពីពិការភាពរបស់អ្នក ដោយបុគ្គលនេះ ត្រូវប្រាប់អំពីការកែសម្រួល ឬការកែតម្រូវណាមួយដែលសមរម្យចំពោះអ្នក ។

## 7. តើខ្ញុំអាចទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយប្រភេទណាពីក្រុមហ៊ុនឯកជន?

ឧបករណ៍បច្ចេកវិជ្ជាជំនួយ មានរួមបញ្ចូលនូវឧបករណ៍ ប្រព័ន្ធ ឬសេវាកម្មណាមួយ ដែលអាចជួយអ្នកឲ្យទទួលបានសេវាកម្មរបស់ក្រុមហ៊ុននោះ ។ ជំនួយទាំងអស់នេះ ជាធម្មតា តាមផ្លូវច្បាប់គេក៏ហៅថាឧបករណ៍ និងសេវាកម្មជំនួយដែរ ។ ឧទាហរណ៍ចំពោះឧបករណ៍បច្ចេកវិជ្ជាជំនួយ មានដូចជាជម្រាលជណ្ដើរ ឧបករណ៍ពង្រីកសម្លេង ចំណងជើងបើក និងបិទ ឧបករណ៍ជំនួយក្នុងការស្ដាប់ អេក្រង់បង្ហាញវីដេអូជាអក្សរ និងប្រព័ន្ធទំនាក់ទំនងដទៃទៀត ។

ក្រុមហ៊ុនឯកជនមិនចាំបាច់ត្រូវផ្ដល់ឧបករណ៍តម្រូវតាម បុគ្គលម្នាក់ៗ ឬឧបករណ៍ដទៃដែលតម្រូវការតាមលក្ខណៈបុគ្គលឡើយ ។ ឧបករណ៍ទាំងអស់នោះ មានដូចជាកៅអីកង់ ឧបករណ៍វេជ្ជសាស្ត្រដែលប្រើបានយូរ ឧបករណ៍ជំនួយការស្ដាប់ដាក់ជាប់នឹងត្រចៀក ឬឧបករណ៍អវយវៈសិប្បនិម្មិត ។ ចំពោះបទបញ្ញត្តិនេះ ក៏មានការលើកលែងដែរ ។ ឧទាហរណ៍ អង្គភាពមួយដែលរៀបចំសន្និបាត នៅឯមជ្ឈមណ្ឌលសន្និបាត អាចត្រូវផ្ដល់ជូននូវឧបករណ៍ជំនួយការស្ដាប់ សម្រាប់អ្នកចូលរួមដែលពិបាកស្ដាប់ ។

ការស្វែងរកការកែសម្រួល បច្ចេកវិជ្ជា ឬឧបករណ៍ដែលត្រឹមត្រូវ ដើម្បីជួយអ្នកឲ្យអាចមានភាពស្មើគ្នាក្នុងការរីករាយជាមួយនឹងទំនិញ ឬសេវាកម្មរបស់ក្រុមហ៊ុន ត្រូវពាក់ព័ន្ធ នឹងដំណើរការអន្តរកម្មរវាងអ្នក និងក្រុមហ៊ុនឯកជន ដែលអ្នកទាំងពីរត្រូវពិភាក្សាគ្នាអំពីជម្រើសនានា ។ សំណើរបស់អ្នកត្រូវទទួលបានការពិចារណាជាចម្បង តែជាចុងក្រោយ ក្រុមហ៊ុនឯកជនអាចជ្រើសយកក្នុងចំណោមជម្រើសនានា ដរាបណាលទ្ធផលដែលទទួលបានគឺមានប្រសិទ្ធិភាពក្នុងការធ្វើឲ្យអ្នកអាចប្រើសេវាកម្ម ឬទំនិញរបស់ក្រុមហ៊ុននេះបាន ។

## 8. តើនៅពេលណាដែលក្រុមហ៊ុនឯកជនមិនត្រូវផ្ដល់ឧបករណ៍បច្ចេកវិជ្ជាជំនួយ?

**<u>ច្បាប់រដ្ឋាភិបាលសហព័ន្ធ</u>**

ស្ថិតក្រោម ADA ក្រុមហ៊ុនឯកជន មិនចាំបាច់ត្រូវផ្ដល់ឧបករណ៍បច្ចេកវិជ្ជាជំនួយឡើយ នៅពេលដែលឧបករណ៍នោះវាអាចធ្វើឲ្យមានការប្រែប្រួលមូលដ្ឋានគ្រឹះនៃមុខជំនួញ ឬវាបង្កឲ្យមានបន្ទុកហិរញ្ញវត្ថុធ្ងន់ធ្ងរ ។ ការកែប្រែមូលដ្ឋានគ្រឹះ គឺជាការផ្លាស់ប្ដូរដែលវាមានភាពសំខាន់ខ្លាំង ដោយវាធ្វើឲ្យមានការប្រែប្រួលលក្ខណៈចាំបាច់របស់ទំនិញ សេវាកម្ម អគារ ឯកសិទ្ធិ

អត្ថប្រយោជន៍ និងការកែតម្រូវនូវមុខជំនួញ ។ ស្ថានភាពបែបនេះ មិនងាយកើតឡើងឡើយ ។ បន្ទុកធ្ងន់ធ្ងរមានន័យថា ជាការលំបាក ឬជាការចំណាយធំរបស់ក្រុមហ៊ុន ដោយគិតអំពីធនធានដែលមាន ហើយនិងផលប៉ះពាល់ចំពោះសំណើសុំកែសម្រួលចំពោះធនធាន ប្រតិបត្តិការ និងការពិចារណាចំពោះសុវត្ថិភាពរបស់ក្រុមហ៊ុន ។ 28 C.F.R. វគ្គទី 36.104 ។ ក្រុមហ៊ុនឯកជនក៏មិនចាំបាច់ត្រូវផ្តល់ឧបករណ៍បច្ចេកវិជ្ជាជំនួយឲ្យដែរ ប្រសិនបើបុគ្គល ឬឧបករណ៍បច្ចេកវិជ្ជាជំនួយវាបង្កឲ្យមានការគម្រាមកំហែងដោយផ្ទាល់ចំពោះសុខភាព និងសុវត្ថិភាពចំពោះអ្នកដទៃ ។ 28 C.F.R. វគ្គទី 36.208 ។

បើក្រុមហ៊ុនឯកជនកំណត់ឃើញថា ការផ្តល់ជូននូវការកែសម្រួល វានឹងនាំឲ្យមានការកែប្រែមូលដ្ឋានគ្រឹះមុខជំនួញរបស់ខ្លួន បង្កឲ្យមានបន្ទុកធ្ងន់ធ្ងរ ឬបង្កឲ្យមានការគម្រាមកំហែងដោយផ្ទាល់ ក្រុមហ៊ុននេះត្រូវផ្តល់ឲ្យអ្នកនូវជម្រើសផ្សេងទៀតចំពោះឧបករណ៍បច្ចេកវិជ្ជាជំនួយ ឬការកែសម្រួលដែលសមរម្យ បើសិនជាមាន ហើយវាមិនបណ្តាលឲ្យមានការកែប្រែជាមូលដ្ឋានគ្រឹះ បង្កឲ្យមានការគម្រាមកំហែង ឬបណ្តាលឲ្យមានបន្ទុកធ្ងន់ធ្ងរចំពោះក្រុមហ៊ុនខ្លួន ។

**<u>ច្បាប់រដ្ឋាភិបាលរដ្ឋ</u>**

ស្ថិតក្រោមច្បាប់រដ្ឋ Section 54 និងក្រោម Unruh គឺមិនមាននិយាយជាក់លាក់ពីការជជែកវែកញែកពាក់ព័ន្ធនឹងបន្ទុកធ្ងន់ធ្ងរ និងការកែប្រែមូលដ្ឋានគ្រឹះឡើយ ។ ការប្រព្រឹត្តិបំពានណាមួយចំពោះ ADA ក៏ជាការប្រព្រឹត្តបំពានចំពោះច្បាប់រដ្ឋ ដោយសារថាច្បាប់រដ្ឋមានវិសាលភាពធំជាង ADA ។

## 9. តើក្រុមហ៊ុនឯកជនអាចទារថ្លៃពីខ្ញុំចំពោះការចំណាយលើឧបករណ៍បច្ចេកវិជ្ជាជំនួយដែរឬទេ?

ទេ ។ ក្រុមហ៊ុនឯកជន មិនអាចកំនត់តម្លៃសម្រាប់ទារពីបុគ្គលណាម្នាក់ ឬក្រុមនៃបុគ្គលណាមួយដែលមានពិការភាព ឲ្យចេញថ្លៃការចំណាយចំពោះឧបករណ៍ជំនួយ ឬការកែសម្រួលសមហេតុផលណាមួយចំពោះគោលនយោបាយ ការអនុវត្ត ឬទម្រង់ការបានឡើយ ។ 28 C.F.R. វគ្គទី 36.301 ។

## 10. តើខ្ញុំត្រូវធ្វើអ្វី ប្រសិនបើក្រុមហ៊ុនឯកជនបដិសេធសំណើសុំឧបករណ៍បច្ចេកវិជ្ជាជំនួយរបស់ខ្ញុំ?

ជាទូទៅ គឺមានរបស់បីយ៉ាងដែលអ្នកត្រូវធ្វើ ប្រសិនបើក្រុមហ៊ុនឯកជនមិនព្រមផ្ដល់ឲ្យអ្នកនូវឧបករណ៍បច្ចេកវិជ្ជាជំនួយ ៖ ដាក់ពាក្យបណ្ដឹងរដ្ឋបាលទៅកាន់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក (DOJ, United States Department of Justice) (ចំពោះការប្រព្រឹត្តិល្មើសលើច្បាប់សហព័ន្ធ) ដាក់ពាក្យបណ្ដឹងរដ្ឋបាលទៅកាន់នាយកដ្ឋានយុត្តិធម៌ការងារ និងជម្រកនៃរដ្ឋកាលីហ្វ័រនីញ៉ា (California Department of Fair Employment and Housing) (សម្រាប់ការប្រព្រឹត្តិល្មើសច្បាប់រដ្ឋ) ឬដាក់ពាក្យប្ដឹងផ្លូវច្បាប់ឯកជន ។ បណ្ដឹងរដ្ឋបាល គឺមិនមានភាពដូចគ្នានឹងបណ្ដឹងផ្លូវច្បាប់ឡើយ ។ អ្នកអាចដាក់ពាក្យប្ដឹងរដ្ឋបាល ឬប្ដឹងផ្លូវច្បាប់ ដោយមិនចាំបាច់មានមេធាវី តែបើអ្នកទាក់ទងជាមួយនឹងមេធាវីមុនការដាក់ពាក្យប្ដឹង គឺជាការប្រសើរ ជាពិសេសគឺស្ដីអំពីដែនកំណត់ពេលវេលាចំពោះការដាក់ពាក្យបណ្ដឹង ។

**<u>ការប្រព្រឹត្តិល្មើសច្បាប់សហព័ន្ធ – បណ្ដឹងរដ្ឋបាល</u>**

ដើម្បីដាក់ពាក្យបណ្ដឹងចំពោះការប្រព្រឹត្តល្មើស ADA ឬ Section 504 ចំពោះក្រុមហ៊ុនឯកជន អ្នកអាចដាក់ពាក្យប្ដឹងមកកាន់ក្រសួងយុត្តិធម៌ ។ អ្នកអាចប្ដឹងតាមប្រៃសនី ឬផ្ញើទូរសារមកកាន់ ៖

1. សូមសរសេរបណ្ដឹងរួចផ្ញើទៅកាន់ ៖

   U.S. Department of Justice
   950 Pennsylvania Avenue, NW
   Civil Rights Division
   Disability Rights Section – 1425 NYAV
   Washington, D.C. 20530

2. សូមផ្ញើពាក្យបណ្ដឹងតាមទូរសារទៅកាន់ ៖ (202) 307-1197

ព័ត៌មានបន្ថែមស្ដីអំពីការដាក់ពាក្យបណ្ដឹងចំពោះការប្រព្រឹត្តល្មើស ADA ទៅកាន់ក្រសួងយុត្តិធម៌ បូករួមទាំងប្រភេទព័ត៌មានដែលអ្នកត្រូវដាក់បញ្ចូលក្នុងពាក្យបណ្ដឹង និងពេលវេលាដែលអ្នកមានដើម្បីដាក់ពាក្យបណ្ដឹង គឺមាននៅឯវិបសៃត៍របស់ក្រសួងយុត្តិធម៌ តាមអាសយដ្ឋាន ៖ http://www.ada.gov/fact_on_complaint.htm ។

## ការប្រព្រឹត្តល្មើសច្បាប់រដ្ឋ – បណ្តឹងរដ្ឋបាល

អ្នកអាចប្តឹងការទាមទារថ្លៃចំណាយ ក្រោមក្រុមអ៊ុនរ៉ុ ឬក្រុមវគ្គទី 54 ដោយការដាក់ពាក្យប្តឹងទៅកាន់នាយកដ្ឋានយុត្តិធម៌ការងារ និងទីជម្រករដ្ឋកាលីហ្វ័រនីញ៉ា (DFEH, California Department of Fair Employment and Housing) ។ អ្នកត្រូវដាក់ពាក្យបណ្តឹងមកកាន់ DFEH ឲ្យបានក្នុងរវាងមួយឆ្នាំ គិតចាប់ពីពេលសកម្មភាពរើសអើងបានកើតឡើង ។ អ្នកអាចដាក់ពាក្យបណ្តឹងតាមអនឡាញ តាមទូរស័ព្ទ ឬតាមប្រៃសនីដូចខាងក្រោម ៖

1. សូមប្រើប្រព័ន្ធអនឡាញរបស់ DFEH តាមអាសយដ្ឋាន http://houdiniesq.net/dfeh/intake/
2. ហៅទូរស័ព្ទមកកាន់មជ្ឈមណ្ឌលទូរគមនាគមន៍របស់ នាយកដ្ឋានយុត្តិធម៌ការងារ និងទីជម្រករដ្ឋកាលីហ្វ័រនីញ៉ា តាមលេខ (800) 884-1684 ។ បើអ្នកមានពិការភាពចំពោះការស្តាប់ អ្នកអាចហៅទូរស័ព្ទមកលេខ (800) 884-1684 ឬអ្នកប្រើ TTY សូមហៅមកលេខ (800) 700-2320 ។
3. ស្នើសុំបែបបទការសាកសួរមុនការដាក់ពាក្យប្តឹង ឬយកសំណុំបែបបទនេះតាមអនឡាញបាននៅឯ http://www.dfeh.ca.gov/res/docs/PCI/Pre%20Complaint%20Inquiry%20-%20DPA.pdf ហើយផ្ញើវាទៅកាន់ការិយាល័យណាមួយរបស់ DFEH ។
4. អ្នកអាចផ្ញើ តាមអ៊ីម៉េលនូវបែបបទសាកសួរមុនការប្តឹងទៅកាន់អាសយដ្ឋាន contact.center@dfeh.ca.gov

ព័ត៌មានបន្ថែម ស្តីអំពីការដាក់ពាក្យបណ្តឹងទៅកាន់នាយកដ្ឋានយុត្តិធម៌ការងារ និងទីជម្រករដ្ឋកាលីហ្វ័រនីញ៉ា បូករួមទាំងប្រភេទព័ត៌មាន ដែលអ្នកត្រូវដាក់បញ្ចូលក្នុងពាក្យបណ្តឹងរបស់អ្នក និងចំនួនពេលវេលាដែលអ្នកមានដើម្បីដាក់ពាក្យបណ្តឹង គឺមាននៅឯ http://www.dfeh.ca.gov/Complaints_ComplaintProcess.htm ។

## បណ្តឹងច្បាប់

អ្នកមិនចាំបាច់ដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់ភ្នាក់ងារណាមួយដូចបានរាយពីខាងលើឡើយ ។ អ្នកអាចដាក់ពាក្យប្តឹងតាមផ្លូវច្បាប់តែម្តង ។ ស្ថិតក្រោមច្បាប់រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលសហព័ន្ធ បណ្តឹងត្រូវដាក់ទៅកាន់តុលាការ

ក្នុងរវាងពីរឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទដែលសកម្មភាពរើសអើង បានកើតឡើង ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* [http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html](http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html) ។

## 11. តើមានធនធានណាខ្លះទៀត?

### ធនធាននានា

1. [http://www.dds.ca.gov/AT/at_network.cfm](http://www.dds.ca.gov/AT/at_network.cfm)
   បណ្តាញបច្ចេកវិជ្ជាជំនួយរដ្ឋកាលីហ្វ័រនីញ៉ា, (California Assistive Technology Network) នាយកដ្ឋានស្តានីតិសម្បទា, (DOR, Department of Rehabilitation) ដោយភ្ជាប់ជាមួយនឹងអ្នកប្រើប្រាស់ បច្ចេកវិជ្ជាជំនួយ, (AT, Assistive Technology), អ្នកផ្តល់ AT និងភ្នាក់ងាររដ្ឋ ជាអ្នកសម្របសម្រួលកិច្ចខិតខំរបស់រដ្ឋកាលីហ្វ័រនីញ៉ា ដើម្បីពង្រីក និងបង្កើនការប្រើប្រាស់ AT ក្រោមក្រមបច្ចេកវិជ្ជា (Tech Act) ឆ្នាំ 1993 ។
   បេសកម្មចម្បងរបស់បណ្តាញប AT រដ្ឋកាលីហ្វ័រនីញ៉ា គឺ ៖

   a. ជួយកាត់បន្ថយឧបសគ្គរបស់ជនពិការក្នុងការទទួលបាន AT ។

   b. លើកកម្ពស់ការយល់ដឹងសាធារណៈអំពីផលប្រយោជន៍របស់ AT ចំពោះជនពិការ ។

   c. រៀបចំយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយភាពជាន់គ្នានៃសកម្មភាពរបស់ភ្នាក់ងាររដ្ឋ និងអង្គការដទៃទៀតទាំងអស់ដែលជាអ្នកជួយជនពិការ ។

   បណ្តាញ AT រក្សាទុកទិន្នន័យអំពីធនធាន AT និងអ្នកផ្តល់ឧបករណ៍នេះ ដែលមានទីតាំងនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ហើយអាចជួយរកទីកន្លែងប្រភព AT សម្រាប់ពិការភាពជាក់លាក់ ។ ការបញ្ជូនបន្តក៏នឹងត្រូវធ្វើឡើងដល់ក្រុមដែលជាអ្នកផ្តល់គោលការណ៍ណែនាំអំពី AT និងទៅកាន់ប្រភពអ្នកផ្តល់ជំនួយមូលនិធិ AT ដែលមានសក្តានុពល ។

2. មជ្ឈមណ្ឌលរស់នៅដោយឯករាជ្យរដ្ឋកាលីហ្វ័រនីញ៉ា (California Independent Living Centers) ។ សម្រាប់បញ្ជីឈ្មោះមជ្ឈមណ្ឌលការរស់នៅដោយឯករាជ្យ

តាមខោនធីនីមួយ សូមអាន ៖ http://www.rehab.cahwnet.gov/ILS/ILC-List.html ។

3. www.Askjan.org – ខណៈពេលដែលវិបសៃត៍ របស់រដ្ឋាភិបាលមួយនេះ ត្រូវបានរៀបចំឡើងសម្រាប់ស្ថានភាពការងារ វាក៏មានព័ត៌មានល្អៗស្តីអំពីធនធានឧបករណ៍បច្ចេកវិជ្ជាជំនួយផងដែរ ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។